**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ០៥ សរ

# សារាចរ

## ស្តីពី

## ការបើកប្រាក់សោធនសម្រាប់ និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ យោធិនចូលនិវត្តន៍ យោធិនបាត់បង់សមត្ថភាពពលកម្ម ដែលកំពុងទទួលមុខតំណែងក្នុងមុខងារនយោបាយ

កន្លងមករាជរដ្ឋាភិបាល បានពិនិត្យឃើញថា អតីតមន្ត្រីរាជការ រួមមាននិវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ និងអតីតយុទ្ធជន រួមមានយោធិនចូលនិវត្តន៍ យោធិនបាត់បង់សមត្ថភាពពលកម្ម ដែលមានបទពិសោធន៍ និងស្នាដៃបម្រើជាតិមាតុភូមិត្រូវបានផ្តល់មុខតំណែងក្នុងមុខងារនយោបាយនៅតាមក្រសួង ស្ថាប័ន ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។

ដោយអនុលោមតាមបទប្បញ្ញត្តិ និងលិខិតបទដ្ឋានដែលនៅជាធរមាន និងក្នុងគោលបំណងដើម្បីពង្រឹងការអនុវត្តគោលនយោបាយអភិបាលកិច្ចល្អឱ្យមានប្រសិទ្ធភាព រាជរដ្ឋាភិបាលសូមធ្វើការណែនាំដូចតទៅ ÷

១- គ្រប់ក្រសួង ស្ថាប័ន ត្រូវផ្តល់បញ្ជីរាយនាម និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ យោធិនចូលនិវត្តន៍ យោធិនបាត់បង់សមត្ថភាពពលកម្ម ហើយដែលបច្ចុប្បន្នទទួលមុខតំណែងក្នុងមុខងារនយោបាយ ទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឱ្យបានឆាប់បំផុតជាកំហិត។

២- ចំពោះនិវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ យោធិនចូលនិវត្តន៍ យោធិនបាត់បង់សមត្ថភាពពលកម្មទាំងឡាយណាដែលកំពុងទទួលទាំងប្រាក់សោធនប្រចាំខែ និងទាំងប្រាក់ឧបត្ថម្ភក្នុងមុខងារនយោបាយក្នុងពេលជាមួយគ្នា ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវផ្អាកការបើកប្រាក់សោធនជាបន្ទាន់។ ប្រាក់សោធនទាំងនេះ និងប្រាក់សោធនដែលបានបើករួចហើយជូននិវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ យោធិនចូលនិវត្តន៍ យោធិនបាត់បង់សមត្ថភាពពលកម្មដែលកំពុងទទួលមុខតំណែងក្នុងមុខងារនយោបាយត្រូវបង្វែរចូលថវិកាជាតិវិញជាកំហិត។ និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ យោធិនចូលនិវត្តន៍ យោធិនបាត់បង់សមត្ថភាពពលកម្ម អាចជ្រើសរើសយកប្រាក់ឧបត្ថម្ភណាមួយដែលខ្ពស់ជាង

គេក្នុងចំណោមប្រាក់ឧបត្ថម្ភច្រើនកន្លែង ដោយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីអនុវត្តទៅតាមនីតិវិធី ។

៣- បន្ទាប់ពីបញ្ចប់មុខតំណែងក្នុងមុខងារនយោបាយ និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ យោធិនចូលនិវត្តន៍ យោធិនបាត់បង់សមត្ថភាពពលកម្ម ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីទទួលបានប្រាក់សោធនប្រចាំខែ ចាប់ពីពេលបញ្ចប់មុខតំណែងក្នុងមុខងារនយោបាយតទៅ ។ ប្រាក់សោធនប្រចាំខែ ដែលត្រូវបានផ្អាកក្នុងរយៈពេលកាន់មុខតំណែងក្នុងមុខងារនយោបាយមិនត្រូវបានគិតរំលឹកជូនវិញឡើយ ។

គ្រប់ក្រសួង ស្ថាប័ន ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ត្រូវសហការអនុវត្តសារាចរនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កញ្ញា ឆ្នាំ ២០០៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *គ្រប់ក្រសួង ស្ថាប័ន*
- *គ្រប់សាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*